និន្នាការនៃស្ថានភាពអាហារូបត្ថម្ភក្នុងចំណោមស្ត្រីអាយុពី ១៥-៤៩ឆ្នាំ



ប្រភព: អង្គតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២០១៤

សមាមាត្រស្ត្រីដែលកង្វះអាហារូបត្ថម្ភស្ថិតក្នុងអាយុ១៥-៤៩ឆ្នាំ បានថយចុះខ្លាំងបើប្រៀបធៀបវាងការអង្កេតចំនួនពីរក្នុងឆ្នាំថ្មីៗកន្លងមកនេះជាមួយនឹងការអង្កេតមុនៗ ទោះបីជាយ៉ាងណាក็ដោយ ការរីកសាលជាលនៃបញ្ហាលើសទម្ងន់និងធាត់ ដែលជាទម្រង់មួយនៃការលើសអាហារូបត្ថម្ភបានកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ។

និន្នាការនៃស្ថានភាពអាហារូបត្ថម្ភរបស់កុមារអាយុក្រោម ៥ឆ្នាំ



ប្រភព: អង្គតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២០១៤

ស្ថានភាពពាក់ព័ន្ធនឹងអាហារូបត្ថម្ភរបស់កុមារនៅកម្ពុជាជាងមួយទសវត្សកន្លងមកនេះមានភាពល្អប្រសើរជាងមុន។ ទោះជាស្ថានភាពនេះល្អប្រសើរយ៉ាងណាក็ដោយក็នៅត្រូវការ ការអន្តរាគមន៍បន្ថែម ។

សន្ទស្សន៍វិសមភាពយេនឌ័រ

យោងតាមបាយការណ៍របស់អង្គការ UNDP នៃប្រទេសកម្ពុជា GII (សន្ទស្សន៍វិសមភាពយេនឌ័រ)គឺ0.៤៧៤ នៅក្នុងឆ្នាំ២០១៨។មានន័យថាប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទាបជាងគេក្នុងចំណោមបណ្តាប្រទេសអាស៊ាន។ ដើម្បីសម្រេចបានសមភាពយេនឌ័រ ចាំបាច់ណាស់គឺការខិតខំប្រឹងប្រែងបន្ថែមទៀតនៅក្នុងវិស័យសាធារណៈក็ដូចជាវិស័យឯកជន។

**GII:គឺជាវិធានការផ្ទុះបញ្ចាំងនូវវិសមភាពក្នុងសមិទ្ធផលរវាងស្ត្រី និងបុរស នៅក្នុងផ្នែកសំខាន់ៗចំនួន៣គឺ៖ ផ្នែកសុខភាពបន្តពូជ ការផ្តល់ភាពអង់អាច និងទីផ្សារការងារ។ តម្លៃ ឬចំណាត់ថ្នាក់កាន់តែខ្ពស់គឺបង្ហាញពីគម្លាតយេនឌ័រកាន់តែធំ។*



ប្រភព: របាយការណ៍ UNDP (Human Development Report)

- រៀបចំដោយ: នាយកដ្ឋានផែនការ និងស្ថិតិ ក្រសួងកិច្ចការនារី
- ទូរស័ព្ទ: +855-23 882 047 /+855-17 773 486
- គេហទំព័រ: www.mowa.gov.kh
- ឧបត្ថម្ភដោយ: ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) តាមរយៈគម្រោងបញ្ជ្រាបយេនឌ័រ ដើម្បីបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (PGM-WEE)

អំពើហិង្សាលើស្ត្រី

ស្ត្រី១នាក់ ក្នុងចំណោមស្ត្រី៥នាក់ ដែលមានអាយុ ១៥-៦៤ឆ្នាំ បានទទួលរងនូវអំពើហិង្សាលើរាងកាយ និង/ឬ ផ្លូវភេទដោយដៃគូជិតស្និទ្ធយ៉ាងហោចណាស់ មួយដងក្នុងមួយជីវិតរបស់ពួកគេ។

ស្ត្រី១នាក់ ក្នុងចំណោមស្ត្រី៣នាក់ ដែលមានអាយុ ១៥-៦៤ឆ្នាំ បានទទួលរងនូវការរំលោភបំពានផ្លូវចិត្តពីសំណាក់ដៃគូជិតស្និទ្ធនៅក្នុងជីវិតរបស់ពួកគេ។

ប្រភព: ការអង្គេតថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធន៍ជីវិតរបស់ស្ត្រី នៅកម្ពុជាឆ្នាំ២០១៥

ភាគរយស្ត្រីដែលបានរៀបការរួច អាយុពី ១៥-៤៩ឆ្នាំ ធ្លាប់មានបទពិសោធន៍ទទួលរងនូវអំពើហិង្សាច្រើនប្រភេទពីដៃគូជិតស្និទ្ធ



ប្រភព: អង្គតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២០១៤

យោងតាមលទ្ធផលនៃការអង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ២០១៤ ស្ត្រីជាង៣០% ដែលមានអាយុ ១៥-៤៩ឆ្នាំ ធ្លាប់ទទួលរងនូវអំពើហិង្សាលើផ្នែករាងកាយ ផ្លូវភេទ ផ្លូវចិត្ត និង/ឬសេដ្ឋកិច្ច ពីប្តី/ដៃគូរបស់ពួកគេ ។

ភាគរយស្ត្រីអាយុ ១៥-៤៩ឆ្នាំ ធ្លាប់ទទួលរងនូវអំពើហិង្សាដោយតវិយាបថស្វែងរកជំនួយ



ប្រភព: អង្គតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២០១៤

យោងតាមលទ្ធផលនៃការអង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ២០១៤ មានស្ត្រីជាង៣ក់កណ្តាលធ្លាប់ទទួលរងនូវអំពើហិង្សាលើរាងកាយ ហើយបានស្វែងរកជំនួយដើម្បីបញ្ឈប់អំពើហិង្សា។ ទោះយ៉ាងណាក็ដោយ មានស្ត្រីជាង៦០% ធ្លាប់ទទួលរងអំពើហិង្សាផ្លូវភេទ បានឆ្លើយថាពួកគេមិនបានស្វែងរកជំនួយឬការប្រឹក្សាយោបល់ ពីនរណាម្នាក់ឡើយ។ នេះបង្ហាញថា ពួកគេមានអារម្មណ៍ពិបាកក្នុងការនិយាយឬពិភាក្សាជាមួយនរណាម្នាក់អំពីបញ្ហា៣ក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទ។ បញ្ហានេះគួរតែពិចារណា និងរកវិធានការដើម្បីដោះស្រាយ។

ស្ត្រីនិងការធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ

ភាគរយស្ត្រីដែលមានឋានៈ តួនាទី និងមុខតំណែងជាន់ខ្ពស់នៅក្នុងជួរាជរដ្ឋាភិបាលកម្ពុជា គឺមានចំនួនតិចតួចនៅឡើយបើប្រៀបធៀបទៅនឹងបុរស។



ប្រភព: ព្រះរាជក្រឹត្យចុះថ្ងៃទី១២ខែកញ្ញា ឆ្នាំ២០១៩ និងរបាយការណ៍របស់ក្រុមការងារបញ្ជ្រាបយេនឌ័រនិងស្ថាប័នរាជរដ្ឋាភិបាលផ្សេងៗ ថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០២០។

ភាគរយស្ត្រីដែលជាមន្ត្រីរាជការស៊ីវិលនាពេលបច្ចុប្បន្ន គឺកំពុងតែមានការកើនឡើងគួរឱ្យកត់សម្គាល់។ ទោះជាយ៉ាងណាក็ដោយ ចំនួនមន្ត្រីរាជការជាបុរសគឺមានដល់ទៅជាង៣ក់កណ្តាលនៃចំនួនមន្ត្រីរាជការសរុប។



ប្រភព: ក្រសួងមុខងារសាធារណៈ: គិតត្រឹមខែធ្នូ ឆ្នាំ២០២0

ភាគរយមន្ត្រីរាជការជាស្ត្រី ដែលមានតួនាទីជាអ្នកគ្រប់គ្រង ឬអ្នកដឹកនាំនៅថ្នាក់ជាតិ។ គ្រប់មុខតំណែងទាំងអស់ គឺភាគច្រើនបុរសមានតួនាទីជាអ្នកគ្រប់គ្រង ឬ អ្នកដឹកនាំ។



ប្រភព: ក្រសួងមុខងារសាធារណៈ: គិតត្រឹមខែធ្នូ ឆ្នាំ២០២0

ភាគរយមន្ត្រីរាជការជាស្ត្រី ដែលមានតួនាទីជាអ្នកគ្រប់គ្រង ឬអ្នកដឹកនាំ នៅថ្នាក់ខេត្ត និងស្រុក។ ភាគរយរបស់ស្ត្រីខ្ពស់គឺនៅក្នុងតួនាទី ឬមុខតំណែងជា "អនុប្រធាន" តែប៉ុណ្ណោះ។



ប្រភព: ក្រសួងមុខងារសាធារណៈ: គិតត្រឹមខែធ្នូ ឆ្នាំ២០២0

ស្ថិតយេនឌ័រសំខាន់ៗក្នុងប្រទេសកម្ពុជា

(គតត្រម ខែកុលា ឆ្នាំ២០២១)

ខិត្តប័ណ្ណនេះ បង្ហាញនូវស្ថិតិសំខាន់ៗអំពីស្ត្រី និងបុរស នៅកម្ពុជា ព័ត៌មានដែលបានលើកយកមកបង្ហាញនៅក្នុងខិត្តប័ណ្ណនេះគឺផ្អែកសំខាន់ទៅលើលទ្ធផលនៃការធ្វើជំរឿន ព្រមទាំងការអង្កេតថ្នាក់ជាតិនានា និងទិន្នន័យដែលបានបោះពុម្ពផ្សាយដោយក្រសួង / ស្ថាប័នរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល។

ចំនួនប្រជាជន (ជំរឿនឆ្នាំ២០១៩)

ក្នុងរយៈពេលពីទសវត្សរ៍កន្លងមកនេះ ឃើញថាចំនួនប្រជាជននៅកម្ពុជាការប្រែប្រួល ពិសេសមានការកើនឡើងទាំងស្ត្រី និងបុរស។ ហើយស្ត្រីមានចំនួនច្រើនជាងបុរសបន្តិចបន្តួច។



ប្រភព: ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

យោងតាមលទ្ធផលជំរឿនទូទៅប្រជាជនឆ្នាំ២០១៩ ចំនួនប្រជាជនសរុបនៅកម្ពុជាមានចំនួន ១៥,៥៥២ ៣ន់នាក់ ក្នុងនោះស្ត្រីមាន ៥១.៣% និងបុរស ៤៨.៧%។



ប្រភព: ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

ភាគរយស្ត្រីជាមេគ្រួសារ គឺនៅតែបន្តមានច្រើនជាង ២០% បន្តិចបន្តួច។



ប្រភព: អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ២០១៩/២០

នៅក្នុងឆ្នាំ២០១៩/២០២០ មានប្រមាណ ២១.៥% នៃគ្រួសារសរុបទាំងអស់ដែលមានស្ត្រីជាមេគ្រួសារ។ យ៉ាងហោចណាស់មាន ០១គ្រួសារ ក្នុងចំណោម ០៥គ្រួសារ គឺមានស្ត្រីធ្វើជាមេគ្រួសារ ។

ភាគរយប្រជាជនដែលមានអាយុចាប់ពី១៥ឆ្នាំឡើង បែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ និងភេទ



ប្រភព: ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

ទាំងស្ត្រី និងបុរសដែលរៀបការរួច គឺមានភាគរយច្រើនជាងគេបំផុតរហូតដល់ទៅ ៦០%។ សមាមាត្រនៃអ្នកមេម៉ាយ / ពោះម៉ាយ និងអ្នកដែលរស់នៅផ្សេងគ្នាគឺភាគរយស្ត្រីខ្ពស់ជាងបុរស។

វិស័យអប់រំ

អត្រាអក្ខរកម្មប្រជាជនពេញវ័យ (អាយុ១៥ឆ្នាំឡើង) បែងចែកតាមភេទ



ប្រភព: អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ២០១៩ / ២០២០

អត្រាអក្ខរកម្មរបស់ស្ត្រី គឺកំពុងតែមានភាពល្អប្រសើរបន្តិចម្តងៗជាលំដាប់ ទោះបីជានៅមានគម្លាតខុសគ្នាបន្តិចបន្តួចក៏ដោយ បើប្រៀបធៀបជាមួយនឹងបុរស។

អត្រាអក្ខរកម្មរបស់ស្ត្រីបែងចែកទៅតាមតំបន់ភូមិសាស្ត្រ



ប្រភព: ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

អត្រាអក្ខរកម្មរបស់ស្ត្រីគឺមានភាពខុសគ្នានៅតាមតំបន់ ដូចជានៅតំបន់ទីប្រជុំជនគឺមានដល់ទៅជាង៩០% ចំណែកតំបន់ជនបទវិញមានតែ៨០.២%។ នោះមានន័យថា នៅតំបន់ជនបទគឺមានស្ត្រី០១នាក់ក្នុងចំណោមស្ត្រី០៥នាក់ គឺគាត់មិនចេះអក្សរ។

អត្រាពិតនៃការសិក្សារបស់សិស្សប្រុស និងសិស្សស្រីនៅតាមគ្រឹះស្ថានសិក្សាអប់រំសាធារណៈ (ឆ្នាំ២០១៨ / ២០១៩)



ប្រភព: ក្រសួងអប់រំ យុវជននិងកីឬា នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ឆ្នាំសិក្សា២០១៨-២០១៩

អត្រាចុះឈ្មោះចូលរៀនរបស់ក្មេងប្រុសគឺខ្ពស់ជាងក្មេងស្រីទាំងក្នុងកម្រិតមត្តេយ្យសិក្សា និងបឋមសិក្សា។ ប៉ុន្តែនៅកម្រិតអនុវិទ្យាល័យ និងវិទ្យាល័យវិញការចុះឈ្មោះចូលរៀនរបស់ក្មេងស្រីគឺមានចំនួនច្រើនជាងក្មេងប្រុស។ អត្រានេះមានភាពខុសគ្នាគួរឱ្យកត់សម្គាល់រវាងក្មេងប្រុស និងក្មេងស្រីនៅកម្រិតសិក្សាអនុវិទ្យាល័យ និងវិទ្យាល័យ។ មូលហេតុនេះអាចបណ្តាលមកពីក្មេងប្រុសភាគច្រើនទៅចុះឈ្មោះចូលរៀននៅសាលាឯកជនវិញ។

អត្រាបោះបង់ចោលការសិក្សារបស់សិស្សប្រុស និងសិស្សស្រីតាមគ្រឹះស្ថានសិក្សាអប់រំសាធារណៈ (ឆ្នាំ២០១៨/២០១៩)



ប្រភព: ក្រសួងអប់រំ យុវជននិងកីឬា នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ឆ្នាំសិក្សា ២០១៨-២០១៩

នៅគ្រប់កម្រិតសិក្សាទាំងអស់ អត្រានៃការបោះបង់ចោលសាលារបស់ក្មេងស្រីគឺមានកម្រិតទាបជាងក្មេងប្រុស។

ការចុះឈ្មោះចូលរៀនរបស់សិស្សស្ត្រីនៅថ្នាក់ឧត្តមសិក្សាឆ្នាំ២០១៩/២០២០



ប្រភព: ក្រសួងអប់រំយុវជននិងកីឬា នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ឆ្នាំសិក្សា២០១៩-២០២០

ភាគរយស្ត្រីដែលបានចុះឈ្មោះចូលរៀននៅថ្នាក់បរិញ្ញាបត្រគឺមានប្រមាណ៥០.៧% ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់២៤.៤% និងថ្នាក់បណ្ឌិត៧.៣% នៅក្នុងឆ្នាំ២០២០។ ទោះបីជាអត្រាចុះឈ្មោះចូលរៀនរបស់ស្ត្រីនៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានកម្រិតទាបនៅឡើយ ប៉ុន្តែភាគរយរបស់ស្ត្រីដែលបានចូលរៀននៅថ្នាក់ឧត្តមសិក្សាកំពុងតែមានការកើនឡើងជាបន្តបន្ទាប់។

វិស័យសេដ្ឋកិច្ច

អត្រាចូលរួមកម្លាំងពលកម្ម អាយុពី ១៥-៦៤ឆ្នាំ បែងចែកតាមភេទ និងឆ្នាំ



ប្រភព: អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ២០១៩/២០

យោងតាមលទ្ធផលនៃការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ២០១៩ / ២០២០ អត្រាចូលរួមកម្លាំងពលកម្មរបស់ស្ត្រីមាន៨៤.១% និងបុរសមាន៩១.០%។ ក្នុងប៉ុន្មានឆ្នាំថ្មីៗចុងក្រោយនេះឃើញថាអត្រាចូលរួមកម្លាំងពលកម្មរបស់ស្ត្រីមានការកើនឡើងខ្ពស់ពិសេសក្នុងឆ្នាំ ២០១៩ / ២០២០ នេះ។ គួរឱ្យកត់សម្គាល់ផងដែរថា អត្រាចូលរួមកម្លាំងពលកម្មរបស់ស្ត្រី កំពុងតែមានការកើនឡើងខ្ពស់បើធៀបទៅនឹងបុរស។

ភាគរយស្ត្រីធ្វើការងារមានប្រាក់កម្រៃក្នុងចំណោមប្រជាជនមានការងារធ្វើ អាយុ១៥-៦៤ឆ្នាំ



ប្រភព: អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ២០១៩/២០២០

យោងតាមលទ្ធផលនៃការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ស្ត្រីដែលធ្វើការងារមានប្រាក់កម្រៃនៅក្នុងវិស័យសេវាកម្មគឺមាន(៣៧.៨%) បន្ទាប់មកគឺនៅក្នុងវិស័យកសិកម្ម(៣៨.០%) និងឧស្សាហកម្ម(២៤.២%)។ នៅតំបន់ទីប្រជុំជនរួមទាំងរាជធានីភ្នំពេញ ស្ត្រីភាគច្រើនគឺធ្វើការក្នុងវិស័យសេវាកម្ម។ ម្យ៉ាងវិញទៀតមានស្ត្រីច្រើនជាង៥០% ដែលប្រកបរបរកសិកម្មនៅតំបន់ជនបទ។ ហើយតួលេខទាំងនេះបង្ហាញនូវភាពខុសគ្នាជាក់ស្តែងរវាងអ្នករស់នៅតំបន់ទីប្រជុំជន និងជនបទ។

វិស័យសុខាភិបាល

អាយុកាលសង្ឃឹមរស់របស់ស្ត្រី និងបុរសនៅកម្ពុជា



ប្រភព: អង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២០០០-២០១៤ និងជំរឿនប្រជាជនឆ្នាំ២០១៩

អាយុកាលសង្ឃឹមរស់របស់ស្ត្រីបានឈានដល់ ៧៦.៨ឆ្នាំ និងបុរស ៧៤.៣ឆ្នាំ សម្រាប់ឆ្នាំ២០១៩។ អត្រានេះកំពុងតែមានការកើនឡើងជាបន្តបន្ទាប់ទាំងស្ត្រី និងបុរស។

និន្នាការនៅក្នុងអត្រាមរណភាពមាតា និងទារក



ប្រភព: អង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២០១៤

* **អត្រាមរណភាពទារក៖** មរណភាពកុមារអាយុក្រោម ០១ឆ្នាំ ក្នុងអត្រាកំណើតរស់ចំនួន១,០០០នាក់

* **អត្រាមរណភាពមាតា៖** មរណភាពមាតាក្នុងអត្រាកំណើតរស់ចំនួន១០០,០០០នាក់។

អត្រាមរណភាពមាតាមានការថយចុះពី ៤៧២នាក់ ក្នុងឆ្នាំ២០០៥ មកនៅត្រឹម ២០៦នាក់ ក្នុងឆ្នាំ២០១០ ហើយអត្រានេះនៅតែបន្តថយចុះមកនៅត្រឹម ១៤១នាក់ ក្នុងឆ្នាំ២០១៩។ អត្រាមរណភាពទារកមានការថយចុះពី ៩៥នាក់ ក្នុងឆ្នាំ២០០០ មកនៅត្រឹម៤៥នាក់ ក្នុងឆ្នាំ២០១០ និងបន្តថយចុះនៅត្រឹម ១៨នាក់ក្នុងឆ្នាំ២០១៩ ។ សូចនាករទាំងពីរនេះមានភាពប្រសើរឡើងគួរ ឱ្យកត់សម្គាល់ ។

ចំណេះដឹងស្តីពីការទប់ស្កាត់ការរីករាលដាលនៃមេរោគហ៊ីវ / អេដស៍ បែងចែកតាមភេទ



ប្រភព: អង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២០១៤

ស្ត្រីប្រមាណច្រើនជាង៨០% និងបុរស៩០% ដែលមានអាយុ១៥-៤៩ឆ្នាំ ដឹងថាការប្រើប្រាស់ស្រោមអនាម័យអាចកាត់បន្ថយហានិភ័យនៃការឆ្លងមេរោគអេដស៍ និងការរួមភេទជាមួយដៃគូតែមួយក៏អាចជួយកាត់បន្ថយការឆ្លងមេរោគហ៊ីវ/អេដស៍ផងដែរ។